**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ភាគីដាក់ឯកសារ:** សហមេធាវីរបស់លោក នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Feb-2016, 14:58
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សម្ងាត់

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

## សំណើរដំបូងលើវិធាន ៨៧(៤) របស់នួន ជា ស្នើសុំឲ្យទទួលយកឯកសារចំនួន ១៥ទាក់ទងនឹង សក្ខីកម្ម អ៊ីសា ឧស្មាន (2-TCE-95)

## (អំពីប្រវត្តិ ភាពឯករាជ និងភាពមិនលម្អៀង និង ចំនួនមនុស្សស្លាប់)

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រំ ផល្លា
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI

**ចម្លងជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អវតក សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") សូមដាក់សំណើនេះសុំឲ្យទទួលយកឯកសារចំនួន ១ ជាភស្តុតាង ទាក់ទងនឹងប្រវត្តិរបស់លោក ឧស្មាន ("ប្រភេទ I") ឯកសារចំនួន ៣ ទាក់ទងទៅនឹងភាពឯករាជ និងមិនលម្អៀងរបស់គាត់ ("ប្រភេទ II") និងឯកសារចំនួនន ១១ ទាក់ទងទៅនឹងការរកឃើញរបស់លោក ឧស្មាននៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា *Oukoubah* ដែលបានលើកឡើងអំពីចំនួនមនុស្សស្លាប់នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ("ប្រភេទ III") ទាំងអស់នេះគឺក្នុងគោលបំណងដើម្បីប្រើប្រាស់នៅក្នុងពេលសួរដេញដោលលោក អ៊ីសា ឧស្មាន (2-TCE-95) ។ ឯកសារដែលត្រូវបានស្នើឡើងនឹងអនុញ្ញាតឲ្យមេធាវីការពារក្តីស្វែងយល់អំពីជំនាញ ភាពមិនលម្អៀង និងឯករាជភាព របស់លោក ឧស្មាន ហើយនឹងពិតជាជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃទៅលើភស្តុតាងដែលផ្តល់ជូនដោយលោក ឧស្មាន។

## II. ច្បាប់ជាធរមាន

2. រាល់ភស្តុតាងទាំងអស់ត្រូវបានទទួលយក លើកលែងតែមានចែងនៅក្នុងវិធានផ្ទៃក្នុង[1]។ អង្គជំនុំជម្រះអាចបដិសេធសំណើទទួលយកភស្តុតាងក្នុងករណីដែលខ្លួនយល់ឃើញថា ភស្តុតាងមិនមានភាពពាក់ព័ន្ធ ឬក៏ច្រំដែល មិនអាចរកបានក្នុងពេលវេលាសមស្រប មិនអាចបង្ហាញទៅលើអង្គហេតុដែលខ្លួនអាចបង្ហាញ មិនអនុញ្ញាតដោយច្បាប់ ឬក៏នាំឲ្យពន្យារពេលដំណើរការ ឬក៏មិនមានប្រយោជន៍[2]។ ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន ៨៧ (៣) ភស្តុតាងដែលត្រូវបានស្នើត្រូវការតែមានភាពពាក់ព័ន្ធ និងអាជឿជាក់បានតាម*ការពិនិត្យបឋម*[3]។ ដោយអនុលោមតាមវិធាន ៨៧ (៤) នៅក្នុងដំណាក់កាលណាក៏ដោយនៅក្នុងអំឡុងពេលសវនាការ ភាគីអាចស្នើសុំឲ្យអង្គជំនុំជម្រះ "ទទួលយកភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" ដែលជាកម្មវត្ថុនៃភាព

---

[1] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[2] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[3] ឯកសារ E289/2 "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយតបរបស់ខៀវ សំផន (ឯកសារ E289/1 )" ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦ ("សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)")។

តម្រូវនៃវិធាន៨៧(៣)[4]។ ខណៈដែលវិធាន ៨៧(៤) ចែងថា ភស្តុតាងដែលត្រូវបានស្នើត្រូវតែមិនអាចរកបាននៅក្នុងនៅមុនពេលបើកសវនាការ អង្គជំនុំជម្រះនេះបកស្រាយថា វាជាភស្តុតាងដែលអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការ ប៉ុន្តែមិនអាចរកឃើញដោយមានការយកចិត្តទុកដាក់សមស្របនឹងអាចទទួលយក[5]។

3. នៅក្នុងស្ថានភាពជាក់ស្តែងភស្តុតាងដែលមិន"លើកឡើងដោយតឹងរ៉ឹង" បំពេញបានលក្ខខណ្ឌនេះត្រូវបានទទួលយក៖ គឺនៅពេលដែលភស្តុតាងមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅឯកសារដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះ និងនៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានប្រភពដើម្បីវាយតម្លៃ, នៅពេលដែលភស្តុតាងដែលលើកឡើងជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃ ដើម្បីកុំឱ្យប៉ះពាល់ដល់យុត្តិធម៌, ឬក៏នៅពេលដែលភាគីផ្សេងទៀតមិនបានបដិសេធនឹងភស្តុតាង[6]។

## III. អំណះអំណាង

### ក. ប្រភេទ I: ឯការទាក់ទងនឹងប្រវត្តិលោក ឧស្មាន

4. ឯកសារ១ ជាវីដេអូរយៈពេល១១នាទី ២០វិនាទី ដែលមានចំណងជើងថា "ជីវប្រវត្តិឧស្មាន" កាលបរិច្ឆេទឆ្នាំ ២០១៤ ដែលលោក ឧស្មាន ពិពណ៌នាអំពីប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិការងាររបស់ខ្លួន។ វីដេអូត្រូវបានដាក់បញ្ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួម ដែលមាន ERN V01198245-V01198245[7]។ ប្រតិចារិកជាភាសាអង់គ្លេសត្រូវបានភ្ជាប់ជាមួយជា **ឧបសម្ព័ន្ធសាធារណៈ១។** វីដេអូត្រូវបានដាក់នៅលើ YouTube នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៤ និងភ្ជាប់ទៅនឹងគេហទំព័ររបស់ ឧស្មាន "Cambodian Village Scholars Fund" ដែលឧស្មានជាបុគ្គលិកមួយរូបដែរ

---

[4] រយៈពេលមួយឆ្នាំនៅក្នុងសវនាការសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ភាគីអាចដាក់សំណើវិធាន ៨៧(៤) ស្នើសុំឱ្យទទួលយកឯកសារដែលមាននៅក្នុងសំណុំរឿង ប៉ុន្តែមិនត្រូវបានបញ្ចូលនៅក្នុងបញ្ជីឯកសារដែលទទួលយកដោយអង្គជំនុំជម្រះ បើទោះជាឯកសារទាំងអស់នោះត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញាដែលនាំឱ្យមានការស្នើឡើង។ សូមមើលប្រតិចារិកថ្ងៃទី២៦ ខែ មករា ឆ្នាំ២០១៦ ទំព័រ ២៥។

[5] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥។ ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

[6] សូមមើល ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

[7] វីដេអូអាចរកបាននៅ https://youtu.be/cfGvzPPPHnI។

[8]។ វីដេអូបង្ហាញពីជីវប្រវត្តិរបស់ ឧស្មាន ដែលគាត់បានរៀបរាប់អំពីប្រវត្តិផ្ទាល់ខ្លួន ការអប់រំ និង បទពិសោធន៍ការងារ។

5. អង្គជំនុំជម្រះបានសម្រេចថា នៅក្នុងសវនាការសំណុំរឿង ០០២/០២ ចាប់ផ្តើមនៅខែ មិថុនា ឆ្នាំ ២០១១[9]។ បទសម្ភាសន៍ត្រូវបានដាក់នៅលើ YouTube នៅថ្ងៃទី១១ ខែ ឧសភា ឆ្នាំ ២០១៤។ អាស្រ័យហេតុហើយគឺមិនអាចរកបាននៅមុនពេលបើកសវនាការ ហើយជាចុងបញ្ចប់គឺបំពេញតាមវិធាន ៨៧(៤)។ បន្ថែមពីលើនេះទៅទៀត ឯកសារ ១ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងឯកសារដែលមានរួចជាស្រេចនៅចំពោះមុខអង្គជំនុំជម្រះ ដោយរួមទាំងសៀវភៅរបស់ ឧស្មាន ផងដែរ[10] និងកំណត់ហេតុស្តាប់ចម្លើយផ្សេងៗទៀតដែលគាត់បានចូលរួមសម្ភាសសម្រាប់ការងាររបស់គាត់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលនាំឱ្យមានកំណត់ហេតុស្តាប់ចម្លើយបុគ្គលទាំងនោះនៅក្នុងសំណុំរឿងក្នុងពេលបច្ចុប្បន្ន[11]។ វីដេអូ គឺមានភាពពាក់ព័ន្ធដើម្បីបញ្ជាក់ពីរបៀបដែលប្រើប្រាស់ដោយលោក ឧស្មាន ក្នុងការសម្ភាសន៍ និងសម្រាប់សៀវភៅរបស់គាត់ និងនាំទៅដល់ភាពអាចជឿជាក់បានលើសៀវភៅ បទសម្ភាសន៍ទាំងនោះ ព្រមទាំងភស្តុតាងដែលផ្តល់ឡើងដោយលោក ឧស្មាន។ អាស្រ័យហេតុនេះហើយ វាជួយក្នុងការស្វែងរកការពិត។

6. លោក ឧស្មាន ជាសាក្សីសំខាន់ក្នុងការផ្តល់សក្ខីកម្មទៅលើការចោទប្រកាន់លើការប្រព្រឹត្តមកលើជនជាតិចាម[12]។ គាត់ជាអ្នកជំនាញតែមួយគត់សម្រាប់បញ្ហានេះ ដែលនឹងឡើងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។ សៀវភៅរបស់គាត់ត្រូវបានប្រើប្រាស់ដោយ កសចស នៅក្នុងពេលដែលកំពុងស៊ើបអង្កេតសំណុំរឿងកំពុងជំនុំជម្រះនេះ និងដោយភាគីនៅក្នុងអំឡុងពេលសួរដេញដោលសាក្សី។ វីដេអូមានភាពពាក់ព័ន្ធក្នុងការបង្ហាញអំពីការទទួលបានចំណេះដឹង និងជំនាញរបស់គាត់ទាក់ទងនឹងការប្រព្រឹត្តមកលើជនជាតិចាម។ បន្ថែមពីលើនេះដូចដែលលោក

---

[8] សូមមើល http://cambodianscholars.org/staff/ysa-osman/។

[9] ឯកសារ **E307/1** "សេចក្តីសម្រេចលើសំណើរួមសុំឱ្យសម្រេច *សាជាថ្មីឡើងវិញ* លើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង" ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១៤ កថាខណ្ឌ ៦។

[10] ឯកសារ **E3/1822** អ៊ីសា ឧស្មាន "*Justice of the Cham Muslims under the Democratic Kampuchea Regime*, 2002 ("*Oukoubah*"); **E3/2653**, Ysa Osman, *The Cham Rebellion: Survivors' Stories from the Village*, 2006

[11] សូមមើលដូចជា **E3/5194** "បទសម្ភាសន៍ជាមួយ AHMAD Sofiyah" ERN 00274708 (EN) និង **E3/8325** "របាយការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស" ថ្ងៃទី២១ ខែ កក្កដា ឆ្នាំ ២០០៨។

[12] ឯកសារ **D427** "ដីកាដំណោះស្រាយ" ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១០ ("ដីកាដំណោះស្រាយ") កថាខណ្ឌ ៧៤៥ ដល់ ៧៩០។

ឧស្មាន នឹងផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីលើអង្គហេតុ វីដេអូមានភាពពាក់ព័ន្ធទៅនឹងផ្នែកនៃភស្តុតាងរបស់ខ្លួនទាក់ទិននឹងប្រវត្តិផ្ទាល់ខ្លួនជា "ជនរងគ្រោះ" នៃបកក។ ជាចុងក្រោយ លោក ឧស្មាន និយាយទៅដល់អំពីប្រល័យពូជសាសន៍ ដែលត្រូវបានចោទប្រកាន់ថាមានមកលើជនជាតិចាម។ ដោយគិតថា អ្នកជំនាញមិនត្រូវបង្ហាញអំពីទស្សនៈទៅបញ្ហាអង្គហេតុហួសហេតុ (ដោយសារមានតែអង្គជំនុំជម្រះតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការកណត់លើបញ្ហានេះ)[13] វីដេអូនេះចាត់ទុកថាជា "សក្ខីកម្មរបស់គាត់នៅពេលមុន" ដែលមេធាវីការពារក្តីមានបំណងសួរដេញដោល។ អាស្រ័យហេតុនេះហើយវានឹងពាក់ព័ន្ធក្នុងការបង្កើតថា អំពីលទ្ធភាពកង្វះភាពឯករាជ និងមិនលម្អៀងរបស់លោក ឧស្មាន។

7. ឯកសារ គឺជាវីដេអូ ដែលងាយស្រួលចំណាំលោក ឧស្មាន។ លោក ឧស្មាន ជាអ្នកសម្របសម្រួលកម្មវិធី នៃ The Cambodia Village Scholars Fund ដែលបានបង្ហោះវីដេអូនៅលើគេហទំព័ររបស់ខ្លួន នៅលើទំព័រមួយដែលដាក់ថា ប្រវត្តិលោក ឧស្មាន។ វីដេអូមានសញ្ញាណនៃយថភាព និងភាពអាចទទួលយកបាន ដែលតម្រូវឲ្យទទួលយកបានជាភស្តុតាង។

## ខ. ប្រភេទ II: ឯកសារទាក់ទងនឹងភាពឯករាជ និងមិនលម្អៀងរបស់លោក ឧស្មាន

### *(i) សេចក្តីសង្ខេបអំពីឯកសារ*

8. ឯកសារ ២ គឺជាសេចក្តីប្រកាសជ្រើសរើសបុគ្គលិករបស់ UNAKRT សម្រាប់តំណែងរបស់គាត់ជា Analyst/Data នៅក្នុង កសចស។ ក្នុងនោះមានសេក្តីសង្ខេបអំពីភារកិច្ចរបស់គាត់សម្រាប់មុខតំណែងនេះ។ វាត្រូវបានភ្ជាប់មកជាមួយជា **ឯកសារភ្ជាប់សាធារណៈ២**។ ឯកសារ៣ គឺជាបញ្ជីសាក្សីទាំងអស់ដែលត្រូវបានសម្ភាសដោយមានវត្តមាន អ៊ីសា ឧស្មាន ដែលមានឈ្មោះ៣៧នាក់ និងកាលបរិច្ឆេទនៃការសម្ភាសន៍[14]។ ឯកសារនេះអាចរកបានដោយមេធាវីការពារក្តីនៅថ្ងៃទី ២៣

---

[13] ឯកសារ **E215** "សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ" ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ១៦ ("សេចក្តីសម្រេចលើអ្នកជំនាញ")។

[14] មានលេខឯកសារ **D361/3.1**។

ខែ មិថុនា ឆ្នាំ២០១០ នៅបន្ទាប់ពីមានដីការបស់ កសចស នៅថ្ងៃទី ១៦ ខែ មិនា ឆ្នាំ ២០១០[15]។ ឯកសារត្រូវបានភ្ជាប់ជា **ឯកសារភ្ជាប់សម្ងាត់ ៣**។

9. ឯកសារ៤ គឺអត្ថបទនៅលើសារព័ត៌មានដែលសរសេរដោយលោក ឧស្មាន មានចំណងជើងថា "ចំនួនជនជាតិចាមត្រូវបានសម្លាប់ជាភស្តុតាងសំខាន់សម្រាប់អំពើប្រល័យពូជសាសន៍" មានកាលបរិច្ឆេទថ្ងៃទី ២០ ខែ មិនា ឆ្នាំ២០០៦។ លោក ឧស្មាន បានបញ្ចេញទស្សនៈរបស់ខ្លួនទៅលើបញ្ហាដែលថា "ខ្មែរក្រហមបានប្រព្រឹត្តអំពីប្រល័យពូជសាសន៍មកលើក្រុមសាសនា និង ជាតិពន្ធភាគតិចនៅប្រទេសកម្ពុជា" ព្រមទាំងបញ្ចេញទស្សនៈទៅលើការពិភាក្សាមួយស្តីអំពីចំនួនជនជាតិចាមដែលបានស្លាប់ ដែលធ្វើឡើងដោយ Kiernan, Hinton និង ប៊ូរា។ ឯកសារត្រូវបានភ្ជាប់ជា **ឯកសារភ្ជាប់សាធារណៈ ៤**។ នៅក្នុងអត្ថបទលោក ឧស្មាន បានប្រើពាក្យដូចជា "បញ្ហាសំខាន់នៃខ្មែរក្រហមបានប្រព្រឹត្តអំពីប្រល័យពូជសាសន៍មកលើក្រុមសាសនា និង ជាតិពន្ធភាគតិចនៅប្រទេសកម្ពុជា" "បញ្ហាប្រល័យពូជសាសន៍នេះ" "ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍"។ តាមការយល់ឃើញរបស់មេធាវីការពារក្តី នេះបង្ហាញឲ្យឃើញអំពីទស្សនៈរបស់គាត់ថា មានអំពីប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាមនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ បន្ថែមពីលើនេះលោក ឧស្មាន ក៏បានធ្វើការឆ្លើយតបផងដែរទៅនឹងអ្នកស្រាវជ្រាវដែលបានជំទាស់ទៅនឹងការរកឃើញរបស់គាត់ទៅលើចំនួនជនជាតិចាមដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

### *(ii) ឯកសារត្រូវតែបានទទួលយកជាភស្តុតាងដើម្បីផលប្រយោជន៍យុត្តិធម៌*

10. បើទោះជាឯកសារមាននៅមុនពេលបើកសវនាការក៏ដោយ ក៏ប៉ុន្តែអង្គជំនុំជម្រះទើបតែបានសម្រេចចាត់លោក ឧស្មាន ជាអ្នកជំនាញនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥នេះទេ។ ហើយគាត់ក៏ត្រូវបានអនុញ្ញាតជាផ្លូវការដោយអង្គការសហប្រជាជាតិនៅថ្ងៃទី២៥ ខែ មករា ឆ្នាំ ២០១៦នេះទេ[16]។ ដោយសារតែឯកសារមានទំនាក់ទំនងជាពិសេស និងដោយផ្ទាល់ទៅនឹងការបង្កើតបានជា

---

[15] ឯកសារ **D361/1** "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធិ អំពីតួនាទីរបស់លោក អ៊ីសា ឧស្មាន នៅក្នុងការស៊ើបអង្កេត អំពីការស្នើសុំឲ្យច្រានចោលចម្លើយរបស់សាក្សីមួយចំនួន និងអំពីការស្នើសុំឲ្យមានការស្តាប់ចម្លើយសាក្សីមួយចំនួនឡើងវិញ" ថ្ងៃទី ១៦ ខែ មិនា ឆ្នាំ២០១០។

[16] **E367/3** លិខិតពីមេធាវីច្បាប់របស់អង្គការសហប្រជាជាតិជូនប្រធានអង្គជំនុំជម្រះសាលាដំបូងអំពី "សំណើសុំដកអភ័យឯកសិទ្ធិរបស់លោក អ៊ីសា ឧស្មាន" ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦ (កាលបរិច្ឆេទថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៦)។

កង្វះភាពឯករាជ និង ភាពមិនលម្អៀង ព្រោះឯកសារទាំងនេះមិនអាចរកបាននៅពេលមុនដោយសារតែបើទោះជាខំប្រឹងប្រែងដោយសមហេតុផល ហើយក៏ដោយសារតែវានៅមិនទាន់ច្បាស់នៅឡើយថា តើគាត់នឹងជាសាក្សី ឬក៏ជាអ្នកជំនាញនៅក្នុងសំណុំរឿងនេះ។ នៅក្នុងកាលៈទេសៈណាក៏ដោយ ឯកសារទាំងនេះទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងឯកសារដែលមានរួចជាស្រេចនៅចំពោះមុខអង្គជំនុំជម្រះ ដោយរួមទាំងសៀវភៅរបស់លោក ឧស្មាន ផងដែរ[17] និងចម្លើយរបស់សាក្សីដែលបានផ្តល់បទសម្ភាសន៍ជូនលោក ឧស្មាន និងបញ្ចូលផ្នែកនៃបទសម្ភាសន៍របស់ខ្លួនទៅក្នុងកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ[18]។ ឯកសារទាំងនេះក៏មានភាពពាក់ព័ន្ធក្នុងការវាយតម្លៃអំពីការចូលរួមរបស់លោក ឧស្មាន នៅក្នុងការស៊ើបអង្កេតនៅក្នុងសំណុំរឿងបច្ចុប្បន្ន និងឈានទៅដល់តម្លៃអាចឲ្យជឿជាក់បាន ព្រមទាំងភស្តុតាងដែលលោក ឧស្មាន ផ្តល់ជូន។ មេធាវីការពារក្តីសូមលើកឡើងថា ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឲ្យអង្គជំនុំជម្រះវាយតម្លៃឯកសារទាំងអស់គ្នា។ ជាចុងបញ្ចប់ការទទួលយកឯកសារទាំងអស់នេះជាភស្តុតាង នឹងជួយដល់អង្គជំនុំជម្រះស្វែងយល់អំពីភាពឯករាជ និងភាពមិនលម្អៀងរបស់លោក ឧស្មាន ព្រមទាំងទម្ងន់នៃភស្តុតាងដែលគាត់ផ្តល់ជូន។ អាស្រ័យហេតុនេះហើយវានឹងជួយដល់ការស្វែងរកការពិត។

***(iii) ឯកសារមានភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ និងអាចជឿជាក់បាន***

11. ឯកសារដែលត្រូវបានស្នើទាំងអស់ទាក់ទងនឹងការចោទប្រកាន់ទៅលើការប្រព្រឹត្តមកលើជនជាតិចាម និងការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍[19]។ បន្ថែមពីលើនេះ ដោយសារតែលោក ឧស្មាន ត្រូវបានចាត់ជាសាក្សីអ្នកជំនាញដោយអង្គជំនុំជម្រះ គាត់មានកាតព្វកិច្ចផ្តល់សក្ខីកម្មចំពោះគ្រប់បញ្ហាទាំងអស់ដែលគាត់ដឹង ឬក៏ជំនាញរបស់គាត់ដែលទាក់ទិននឹងការប្រព្រឹត្តមកលើជនជាតិចាម ដោយអព្យាក្រិត និង ប្រកបដោយវត្ថុវិស័យភាព[20]។ ក្នុងឋានៈជាសាក្សីអ្នកជំនាញលោក ឧស្មាន មិនអាចបង្ហាញពីទស្សនៈទៅលើបញ្ហាកំពូលនៃអង្គហេតុនោះទេ[21]។ ជាពិសេសជាងនេះទៅទៀត ឯកសារប្រភេទ II ទាក់ទងនឹងគុណវុឌ្ឍិ និងតួនាទីរបស់លោក ឧស្មាន នៅក្នុង

---

[17] សូមមើលជើងទំព័រលេខ ១០ ខាងលើ។

[18] សូមមើលជើងទំព័រលេខ ១១ ខាងលើ។

[19] **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៧៤៥ ដល់ ៧៩០។

[20] ឯកសារ **E215** "សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ" កថាខណ្ឌ ១៥។

[21] ឯកសារ **E215** "សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ" កថាខណ្ឌ ១៦។

កសចស (ឯកសារ ២-៣) និងភាពឯករាជ និង ភាពមិនលម្អៀង (ឯកសារ ៤)។ ឯកសារ ២ និង ៣ បង្ហាញថា មានវត្តមាននៅក្នុងពេលស្តាប់ចម្លើយសាក្សីនៅក្នុងសំណុំរឿង ០០២/០២ ដែលកំពុងស៊ើបអង្កេតគឺមិនចិតនៅក្នុងតួនាទីជា Analyst/Data Coder របស់ កសចស នោះទេ។ វាអាចបង្ហាញថា ភស្តុតាងជំនាញរបស់លោក ឧស្មាន គឺធ្វើឱ្យប្រឡាក់ដោយសារការចូលរួមនេះ និងថាមិនអាចផ្តល់សក្ខីកម្មដោយអព្យាក្រិត និង ដោយវត្ថុវិស័យនោះទេ។ ឯកសារ ៤ បង្ហាញថា លោក ឧស្មាន បានធ្វើការសន្និដ្ឋានរួចជាស្រេចទៅហើយទៅលើបញ្ហាស្នូលនៃសំណុំរឿង គឺអំពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម អាស្រ័យហេតុនេះហើយគាត់មានធ្វើសេចក្តីសន្និដ្ឋានទៅដល់បញ្ហាកំពូលនៃអង្គហេតុរួចទៅហើយ ដែលធ្វើឱ្យគាត់មិនអាចផ្តល់សក្ខីកម្មប្រកបដោយអព្យាក្រិត និង វត្ថុវិស័យភាព។ វាអាចបង្ហាញថា ភស្តុតាងជំនាញរបស់លោក ឧស្មាន មានភាពជិតដាម និងអាស្រ័យហេតុនេះហើយ មិនមានតម្លៃនោះទេ។

12. គ្រប់ឯកសារប្រភេទ II គឺមានភាពអាចជឿជាក់បានតាម*ការពិនិត្យបឋម*។ ឯកសារ២ គឺជាឯកសារផ្លូវការរបស់ UNAKRT ដែលអាចរកបានពីគេហទំព័រផ្លូវការ[22] និងឯកសារ៣ គឺជាឯកសារផ្លូវការរបស់ អវតក ចេញមកពី កសចស[23]។ ឯកសារ ៤ ត្រូវបានបោះពុម្ពដោយកាសែតភ្នំពេញប៉ុស្តិ៍ គឺកាសែតដែលមានការទទួលស្គាល់ និងល្បីមួយ។ បន្ថែមពីលើនេះទៀត គឺនៅពេលផ្តល់សក្ខីកម្ម លោក ឧស្មាន ក៏អាចបញ្ជាក់ថា គាត់គឺជាអ្នកនិពន្ធអត្ថបទនេះផងដែរ។

## គ. ប្រភេទ III: ឯកសារទាក់ទងនឹងចំនួនអ្នកស្លាប់ដែលរកឃើញដោយលោក ឧស្មាន

13. នៅក្នុងសៀវភៅរបស់គាត់ លោក ឧស្មាន បានលើកឡើងថា មានចាមច្រើនជាង ៥០០ ០០០ ឬក៏ចំនួន ៧៥% នៃប្រជាជនចាមទាំងអស់ (ដែលគាត់បានប៉ាន់ស្មានថា មាន ៧០០ ០០០ នៅឆ្នាំ ១៩៧៥) ត្រូវបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[24]។ តែទោះជាយ៉ាងណាក៏ដោយ ក៏មានអ្នកស្រាវជ្រាវជាច្រើនបានផ្តល់ព័ត៌មានខុសពីនេះជាច្រើន គឺទាំងនៅមុនពេល និងក្រោយពេលដែលសៀវភៅរបស់លោក ឧស្មាន ត្រូវបានបោះពុម្ព។ ការពិភាក្សាក្នុងចំណោមអ្នកស្រាវជ្រាវបាន

---

[22] អាចរកបាននៅ: http://www.unakrt-online.org/sites/default/files/VA_Analyst%20Data%20Coder%20G-7_0.pdf.

[23] មេធាវីការពារក្តីសូមរក្សាសិទ្ធិជំទាស់នឹងបញ្ជីនេះ និងជាពិសេសដែលសាក្សីដែលត្រូវបានសម្ភាសនៅឆ្នាំ ២០០៧ ដល់ ២០០៨។

[24] **E3/1822**, *Oukoubah*, ទំព័រ២។

ចាប់ផ្តើមឡើងតាំងពីឆ្នាំ ១៩៨៨ និង ២០០៦ ទាក់ទងនឹងចំនួនជនជាតិដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយចំនួនដែលរកឃើញដោយលោក ឧស្មាន គឺជាចំនួនដ៏ច្រើនជាងគេបំផុត។ ឧទាហរណ៍ Michael Vickery រកឃើញតែជនជាតិចាមចំនួន ១៩១ ២០០ តែប៉ុណ្ណោះនៅខែ មេសា ឆ្នាំ១៩៧៥[25]។ សម្រាប់ Ben Kiernan បើទោះជាទស្សនៈរបស់គាត់ថា អំពើប្រល័យពូជសាសន៍ពិតជាកើតមានប្រឆាំងនឹងជនជាតិចាមក៏ដោយ គាត់ក៏ជំទាស់នឹងការរកឃើញរបស់លោក ឧស្មាន ដោយបានលើកឡើងថា "ការរកឃើញរបស់ ឧស្មាន គឺ មានចំនួនដល់ទៅបីដងច្រើនជាងចំនួនពិតប្រាកដ" ហើយបានផ្តល់ថា មានតែជនជាតិចាមចំនួន ២៥០ ០០០ ប៉ុណ្ណោះនៅឆ្នាំ ១៩៧៥ ដែលមានអ្នកស្លាប់តែប្រហែលជា ៩០ ០០០ ប៉ុណ្ណោះនៅក្នុងអំឡុងពេលនោះ[26]។

14. ខុសពីលោក ឧស្មាន ដែលពឹងផ្អែក "ការស្រាវជ្រាវ" របស់ខ្លួនតែទៅលើបទសម្ភាសន៍ដែលគាត់បានជួបជាមួយចាស់ទុំជនជាតិចាម អ្នកស្រាវជ្រាវផ្សេងទៀតបានធ្វើការគិតគូរចំនួននេះដោយបច្ចេកទេស គឺពឹងផ្អែកទៅលើភស្តុតាងពិត ដូចជាជំរឿនប្រជាជនជាដើម។ មេធាវីការពារក្តីសូមលើកឡើងថា ដើម្បីឱ្យអង្គជំនុំជម្រះធ្វើការប៉ាន់ប្រមាណដ៏ត្រឹមត្រូវទៅលើការរកឃើញរបស់លោក ឧស្មាន គឺជាការចាំបាច់ណាស់ក្នុងការដាក់បញ្ចូលការរកឃើញរបស់អ្នកស្រាវជ្រាវផ្សេងទៀតនៅក្នុងការវាយតម្លៃរបស់ខ្លួន។

### *(i) ការសង្ខេប ប្រភេទឯកសារ III*

15. **ឯកសារ ៥: អត្ថបទដែលមានចំណងជើង** ***"Khmer Rouge Genocide Debate Moves to Trial"*** ដោយ ***George Wright*** និង ***Khuon Narim (2015)***: អត្ថបទនេះពិភាក្សាការជំនុំជម្រះដែល(នៅពេលនោះ) មកដល់ឆាប់ៗនេះនៅក្នុងសំណុំរឿង ០០២/០២ ហើយនិពន្ធដោយ ***George Wright*** និង ***Khuon Narim*** ។ អត្ថបទនេះបោះពុម្ពផ្សាយនៅលើព្រឹត្តិប័ត្រ the *Cambodia Daily* នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ និងអាចរកឃើញនៅក្នុង**ឯកសារភ្ជាប់សាធារណៈ៥** ។ អ្នកនិពន្ធសង្ខេបនូវការពិភាក្សារបស់ប្រវត្តិវិទូដែលបានលើកឡើងខាងលើ និងស្រង់សំដីលោក Chandler

---

[25] ឯកសារ ៦ ទំព័រ ៤ (៣២)។

[26] ឯកសារ ១៣ ទំព័រ ៤ (ERN 00488406)។

ដែលបានផ្តល់សក្ខីកម្មជាសាក្សីជំនាញនៅក្នុងសំណុំរឿង ០០២/០១ ហើយដែលអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកយ៉ាងខ្លាំងនៅក្នុងសាលក្រមរបស់ខ្លួន ដែលបាននិយាយថា "ធាតុផ្សំចេតនា មិនអាចបង្ហាញបានទេនៅក្នុងករណីកម្ពុជា"។

16. **ឯកសារ ៦: អត្ថបទមានចំណងជើង "ក្មេងកំព្រានៃអំពើប្រល័យពូជសាសន៍: ជនជាតិអ៊ីស្លាមនៃកម្ពុជានៅក្រោម ប៉ុល ពត"** (*The Cham Muslims of Kampuchea Under Pol Pot*) ដោយ ***Ben Kiernan (1988)***: ក្រុមមេធាវីការពារក្តីស្វែងរកឱ្យទទួលយកអត្ថបទមួយដែលនិពន្ធដោយលោក **Ben Kiernan** នៅឆ្នាំ១៩៨៨ ហើយពាក់ព័ន្ធទៅនឹងជនជាតិចាមនៅកម្ពុជា។ វាអាចរកឃើញនៅក្នុង**ឯកសារភ្ជាប់សាធារណៈ៦** ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុងលេខ ២០, N.4 នៃ the *Critical Asian Studies* លេខខែតុលា-ធ្នូ ឆ្នាំ១៩៨៨ ។ លោក **Kiernan** លើកឡើងថាជនជាតិចាម ១ភាគ៣ ឬ ប្រហែល ៩០.០០០ នាក់ បានស្លាប់ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ។ តួលេខរបស់គាត់ គឺផ្អែកលើ baseline នៃចំនួន ២៥០.០០០ និងតួលេខចុងក្រោយនៃចំនួន ១៧៣.០០០[27]។ អត្ថបទនេះបង្កើតជាមូលដ្ឋាននៃការពិភាក្សារបស់ប្រវត្តិវិទូរវាងលោក Chandler, លោក Kiernan លោក Osman, លោក Vickery លោក បូរា និងលោក Short ពាក់ព័ន្ធទៅនឹងចំនួនមនុស្សស្លាប់នៅក្នុងចំណោមជនជាតិចាមនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ និងថាតើវាបំពេញបាននូវលក្ខណៈសម្បត្តិជាអំពើប្រល័យពូជសាសន៍ដែរ ឬយ៉ាងណា។

17. **ឯកសារ ៧: អត្ថបទមានចំណងជើង "ការអធិប្បាយលើចំនួនជនជាតិចាម** (***Comments on Cham Population Figures***)**" ដោយ** ***Michael Vickery (1990)***: ក្រុមមេធាវីការពារក្តីស្វែងរកឱ្យទទួលយកអត្ថបទមួយនិពន្ធដោយ **Michael Vickery** នៅឆ្នាំ១៩៩០ និងពាក់ព័ន្ធទៅនឹងជនជាតិចាមនៅមុន និង ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ អត្ថបទេះត្រូវបានសរសេរឡើងនៅក្នុងការឆ្លើយតបទៅនឹងអត្ថបទរបស់ **Kiernan** ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៨៨ (សូមមើលឯកសារ៦) វាអាចរកបាននៅក្នុង**ឯកសារភ្ជាប់សារធារណៈ៧** ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុងលេខ ២០, N.1 នៃ the *Critical Asian Studies* លេខខែមករា-មីនា ឆ្នាំ១៩៩០ ។ អត្ថបទនេះបង្កើតជាមូលដ្ឋាននៃការពិភាក្សារបស់ប្រវត្តិវិទូទាក់ទងនឹងថា តើអំពើប្រល័យពូជសាសន៍បានកើតឡើងនៅកម្ពុជានៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ដែរ ឬយ៉ាងណា ដែលរួមទាំងការពិភាក្សាមួយអំពី

---

[27] ឯកសារ ៥ នៅទំព័រ ៣១ សេចក្តីសន្និដ្ឋាន ។

ចំនួនជាមូលដ្ឋានដែលត្រូវបានប្រើប្រាស់ដើម្បីគាំទ្រ ឬ បដិសេធការអះអាងនេះ។

18. លោក **Vickery** ជំទាស់ទៅនឹងចំនួនប្រជាជនដែលផ្តល់ដោយ **Kiernan** នៅក្នុងអត្ថបទឆ្នាំ១៩៨៨ របស់គាត់ ដោយបានថ្លែងថាលោក **Kiernan** បាន "កែប្រែស្ថិតិនៅក្នុងលក្ខណៈលំអៀងក្នុងការប៉ុនប៉ងបង្ហាញករណីប្រល័យពូជសាសន៍នៅក្នុងកម្ពុជាប្រជាធិបតេយ្យ"[28]។ គាត់កត់សម្គាល់ថា:

> ស្ថិតិប្រជាជនកម្ពុជាទាំងអស់នៃសម័យកាលណាក៏ដោយ រួមទាំងវិធានការជាច្រើនដូចជាសម្មតិកម្ម ការស្មាន ការនិយាយជារួម និងការស្មានសុទ្ធសាធ ហើយស្ថិតិនេះនៅតែមិនគ្រប់គ្រាន់សម្រាប់ប្រភេទនៃការគណនាដោយលោក **Kiernan** ឬ រូបខ្ញុំ[29]។

19. ឯកសារនេះពិភាក្សាមូលដ្ឋាននៃការរកឃើញរបស់ **Kiernan** ពាក់ព័ន្ធនឹងប្រជាជនចាមនៅកម្ពុជា និងរិះគន់វិធីសាស្ត្ររបស់ **Kiernan** ។ ជាពិសេសលោក **Vickery** គណនាថានៅខែមេសា ឆ្នាំ ១៩៧៥ ប្រជាជនចាមមានចំនួន ១៩១ ២00នាក់ និងមិនមែន ២៥0 000នាក់ ដូចលោក Osman បានអះអាងនោះទេ ។ កាត់សន្និដ្ឋានថា "ចំនួនប្រហាក់ប្រហែលជាង ១៦៨ 000នាក់ គឺជា*ចំនួនតិចបំផុត* ដែលអាចជាចំនួនសន្មត់សម្រាប់អ្នកនៅរស់ឆ្នាំ១៩៧៩។ តួរលេខទាបណាមួយតម្រូវអត្រាកំណើនខ្ពស់ខ្លាំងដើម្បីទៅដល់ការរាប់ចំនួនប្រជាជននៅក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជានៅឆ្នាំ១៩៨២"[30]។ គាត់សន្និដ្ឋានថា "លើមូលដ្ឋាននៃចំនួនពិតណាមួយ អ្វីដែលមិនអាចទទួលយកបាន គឺថា"មួយភាគបីនៃប្រជាជនចាម ឬប្រហែល ៩0 000នាក់ [២៥0 000-១៧៣ 000= ៧៧ 000 បូក ១0 000 កើតក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ] បានស្លាប់" (**Kiernan** នៅទំព័រ៣0) មិនដែលចាប់ផ្តើមពីចំនួន ២៥0.000 ទេ"[31]

20. **ឯកសារ៨៖ អត្ថបទមានចំណងជើង** ***"Devil's advocate: there should be no KR trial",*** ដោយ ***Philip Short*** (ខែវិច្ឆិកា ឆ្នាំ២000): ក្រុមមេធាវីការពារក្តីស្នើសុំរកឱ្យទទួលយកអត្ថបទមួយនិពន្ធដោយ Philip Short នៅក្នុងព្រឹត្តិប័ត្រភ្នំពេញប៉ុស្តិ៍ ហើយទាក់ទងនឹងការបំពេញលក្ខខណ្ឌនៃអំពើប្រល័យពូជសាសន៍ ទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងនៅកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ និង

---

[28] ឯកសារ ៦ នៅទំព័ ៣ (៣១)។

[29] ឯកសារ ៦ នៅទំព័ ៣ (៣១)។

[30] ឯកសារ ៦ នៅទំព័ ៥ (៣៣)។

[31] ឯកសារ ៦ នៅទំព័ ៥ (៣៣)។

១៩៧៩។ វាអាចរកបាននៅក្នុង**ឯកសារភ្ជាប់សារធារណៈ៨** ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅខែវិច្ឆិកា ឆ្នាំ២000 ហើយបង្កើតជាមូលដ្ឋាននៃការពិភាក្សារបស់ប្រវត្តិវិទូទាក់ទងនឹងអត្ថិភាពនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាពិសេសប្រឆាំងនឹងជនជាតិចាម និងតួលេខជាមូលដ្ឋានដើម្បីគាំទ្រការអះអាងនេះ។

21. នៅក្នុងអត្ថបទរបស់គាត់ លោក Short មានជំហរថាព្រឹត្តិការណ៍នានា ដែលកើតឡើងនៅចន្លោះឆ្នាំ ១៩៧៥ និង១៩៧៩ នៅកម្ពុជា រួមទាំងព្រឹត្តិការណ៍ដែលកើតឡើងទៅលើជនជាតិចាម មិនបំពេញលក្ខណៈសម្បត្តិនៃអំពើប្រល័យពូជសាសន៍នោះទេ។ លោក Short រកយល់ឃើញថា "ពិតណាស់ខ្ញុំជឿជាក់ថា វាពិបាកបង្ហាញនូវការប៉ុនប៉ងជាប្រព័ន្ធដើម្បីសម្លាប់រង្គាលពួកគេ" ទាកទងនឹងការពិភាក្សាពាក្យ "ប្រល័យពូជសាសន៍" លោក Short សរសេរថា:

> ងាយយល់ថាហេតុអ្វីពាក្យ "ប្រល័យពូជសាសន៍" ត្រូវបានប្រើប្រាស់ដោយអ្នកនិពន្ធ និងក្រុម academics ដែលកំពុងខំយ៉ាងខ្លាំងក្នុងការស្វែងរកពាក្យមួយម៉ាត់ដែលពាំនាំនូវភាពធំសម្បើមនៃអ្វីដែលបានកើតឡើងនៅកម្ពុជា។ ពាក្យផ្សេងទៀតហាក់ដូចជាទន់ខ្សោយ និងមិនគ្រប់គ្រាន់ដើម្បីពិពណ៌នាការស្លាប់ និងទុក្ខវេទនាដ៏មហិមាលើប្រទេសមួយនេះ។ ប៉ុន្តែពាក្យមានន័យដូចអ្វីដែលពួកគេនិយាយ ។ ពាក្យទាំងនេះមិនអាចត្រូវគួញដែលអាចធ្វើឲ្យប្រែប្រួលបានដើម្បីក្រសោបនូវន័យថ្មីតាមការចង់បានរបស់នយោបាយបានឡើយ។"ប្រល័យពូជសាសន៍" មានន័យថាការខំប្រឹងដោយដឹងជាមុន ដើម្បីធ្វើឲ្យផុតពូជជាតិសាសន៍មួយ ។ មានអំពើប្រល័យពូជសាសន៍មាននៅប្រទេសរ៉ូហ្វាន់ដា ។ មានអំពើប្រល័យពូជសាសន៏នៅណាហ្សីអាលឺម៉ង់។ ប៉ុន្តែពុំមាននរណាម្នាក់សន្មត់ជាមុនថា ប៉ុល ពត និងសហការីរបស់គាត់មានចេតនាធ្វើឲ្យជាតិខ្មែរផុតពូជនោះទេ ។ អំពើព្រៃផ្សៃដ៏ធំធេង និងការសម្លាប់រង្គាល គឺពិតជាកើតមានមែន តែមិនមានជាអំពើប្រល័យពូជសាសន៏ទេ។

22. **ឯកសារ៩៖ អត្ថបទមានចំណងជើង *"Why did they kill?"* ដោយ ទូច បូរ៉ា (ខែវិច្ឆិកា ២00៥)៖** ក្រុមមេធាវីការពារក្តីស្វែងរកឲ្យទទួលយកអត្ថបទមួយនិពន្ធដោយ ទូច បូរ៉ា នៅក្នុងព្រឹត្តិប័ត្រភ្នំពេញប៉ុស្តិ៍ ហើយទាក់ទងនឹងការបំពេញលក្ខខណ្ឌអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ វាអាចរកបាននៅក្នុង**ឧបសម្ព័ន្ធសារធារណៈ៩** ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២00៥។ លោក បូរ៉ា ជំទាស់ទៅនឹងការលើកឡើងរបស់លោក Hinton ដែលថាអំពើប្រល័យពូជសាសន៍បានកើតឡើងនៅកម្ពុជារវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។ ឯកសារបង្កើតជាមូលដ្ឋាននៃការពិភាក្សារបស់ប្រវត្តិវិទូទាក់ទងនឹងថា តើអំពើប្រល័យជូតសាសន៍បានកើតឡើងនៅកម្ពុជារវាងឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩ ដែរ ឬយ៉ាងណា ដែលរួមបញ្ចូលទាំងការពិភាក្សាពីចំនួនជាមូលដ្ឋាន

ដើម្បីគាំទ្រការអះអាងនេះ។ ជាពិសេសលោក បូរា បានលើកឡើងថា "ពុំមានភស្តុតាងបង្ហាញថា មេដឹកនាំខ្មែរក្រហមមានចេតនាបំផ្លិចបំផ្លាញក្រុមណាមួយ ដោយមូលហេតុពូជសាសន៍ ជាតិ ឬ សាសនាឡើយ។ ពិតមែនហើយសមាជិកមួយនៃក្រុមជាតិពន្ធុ និងសាសនាភាគតិច បានស្លាប់ក្នុង អំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ តែសាកសពរបស់ពួកគេមិនស្មើជាមួយអំពើប្រល័យពូជ សាសន៍ឡើយ"។ ទាក់ទងនឹងជនជាតិចាម លោក បូរា ថ្លែងថា: "មិនមានអ្វី រួមទាំងចម្លើយ សារភាពរបស់ពួកគេ សន្មត់ថា ពួកគេត្រូវបានសម្លាប់ដោយសារពួកគេជាជនជាតិចាមឡើយ ។ ដូចអ្នកទោសជាច្រើនដ៏ទៃទៀតដែរ ពួកគេត្រូវបានចាប់ខ្លួន និង បញ្ជូនមក ស២១ ដោយសារត្រូវ គេឆ្លើយដាក់ថា បានធ្វើសកម្មភាពប្រឆាំងនឹងបដិវត្ត"[32]

23. ជាចុងក្រោយគាត់ជំទាស់ដោយផ្ទាល់ទៅនឹងការរកឃើញរបស់ Osman ដែលថាអំពើប្រល័យពូជ សាសន៍ បានកើតឡើងចំពោះជនជាតិចាម ដោយបានលើកឡើងថា "ភស្តុតាងដែលគាត់ប្រមូល បាន ដូចជាការហាមឃាត់ការគោរពសាសនាអ៊ីស្លាម មិនមែនជាភស្តុតាងនៃអំពើប្រល័យពូជ សាសន៍ឡើយ" ។

24. **ឯកសារ១០៖ អត្ថបទមានចំណងជើង** ***"Evidence of Intent Lacking"*** **ដោយ ទូច បូរា (ខែមករា ២០០៦)៖** ក្រុមមេធាវីការពារក្តីស្វែងរកឱ្យទទួលយកអត្ថបទមួយនិពន្ធដោយ ទូច បូរា ហើយទាក់ទងនឹងតួលេខដែលគាំទ្រការអះអាងថាអំពើប្រល័យពូជសាសន៍បានកើតឡើងនៅកម្ពុជា វាអាចរកបាននៅក្នុង**ឯកសារភ្ជាប់សាធារណៈ១០** ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុង ព្រឹត្តិប័ត្រភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៦ ហើយបង្កើតជាមូលដ្ឋាននៃការពិភាក្សា របស់ប្រវត្តិវិទូទាក់ទងនឹងអត្ថិភាពនៃអំពើប្រល័យពូជសាសន៍ និង តួលេខជាមូលដ្ឋានសម្រាប់គាំទ្រ ការអះអាងនេះ។

25. នៅក្នុងឯកសារ ១០ លោក បូរា ជំទាស់ទៅនឹងប្រភពដែលជាមូលដ្ឋាននៃការអះអាងរបស់លោក Hinton ដែលថាអំពើប្រល័យពូជសាសន៍បានកើតឡើង។ ជាពិសេសគាត់បានជំទាស់នឹងតួលេខ របស់លោក Osman ដែលលោក Hinton បានពឹងផ្អែក ដោយបានថ្លែងថា តួលេខទាំងនេះមិនផ្អែក លើឯកសារភស្តុតាងដែលអាចជឿទុកចិត្តណាមួយនោះទេ។ លោក បូរា ក៏ពិភាក្សាលោក **Kiernan** (សូមមើលឯកសារ៦) និង តួលេខរបស់លោក **Vickery** (សូមមើលឯកសារ៧) ។

---

[32] បញ្ជាក់បន្ថែម ។

លោកបូរា សន្និដ្ឋានដោយថ្លែងថា"អង្គហេតុដែលថាមេដឹកនាំជាន់ខ្ពស់ភាគច្រើននៃកម្ពុជាប្រជាធិបតេយ្យមកពីជាតិពន្ធុផ្សេងៗ (ចិន/វៀតណាម/ចាម) គាំទ្រការកង្វះចេតនាប្រល័យពូជសាសន៍ទៅលើជាតិពន្ធុភាគតិច"។

26. **ឯកសារ១១៖ អត្ថបទមានចំណងជើង** ***"Genocide Definition"*** **ដោយ ទូច បូរា (ខែមីនា ២០០៦)៖** ក្រុមមេធាវីការពារក្តីស្វែងរកឲ្យទទួលយកអត្ថបទមួយនិពន្ធដោយ ទូច បូរា ហើយទាក់ទងនឹងតួលេខដែលជាមូលដ្ឋានសម្រាប់ការលើកឡើងរបស់លោក Hinton ដែលថាអំពើប្រល័យពូជសាសន៍បានកើតឡើងនៅកម្ពុជា ។ វាអាចរកបាននៅក្នុង**ឯកសារភ្ជាប់សារធារណៈ១១** ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិប័ត្រភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៦ និងបង្កើតជាមូលដ្ឋាននៃការពិភាក្សារបស់អ្នកប្រវត្តិវិទូ ទាក់ទងនឹងអត្ថិភាពនៃអំពើប្រល័យពូជសាសន៍ជាពិសេសប្រឆាំងនឹងជនជាតិចាម និង តួលេខជាមូលដ្ឋានសម្រាប់គាំទ្រការអះអាងនេះ។

27. នៅក្នុងឯកសារ ១១ លោក បូរា ដាក់សំណួរអំពីការរកឃើញដោយលោក **Kiernan** ដែល លោក Hinton ក៏បានពឹងផ្អែកដែរ និងច្រានចោលការលើកឡើងថា មានចេតនាប្រល័យពូជសាសន៍ដើម្បីបំផ្លាញជនជាតិចាម ។ គាត់កត់សម្គាល់ថាជាទូទៅអ្នកជំនាញផ្នែកច្បាប់យល់ស្របថា លក្ខណៈវិនិច្ឆ័យពីចំនួនតែឯង មិនមែនជាកត្តាកំណត់នៅក្នុងការបង្ហាញអំពើប្រល័យពូជសាសន៍ទេ ។ ដោយយោងលើឯកសារពី ប.ក.ក លោក បូរា សន្និដ្ឋានថា មិនមានគោលនយោបាយដើម្បីលុបបំបាត់ជនជាតិចាម ឬវៀតណាម ដោយមូលហេតុជាតិពន្ធុរបស់ពួកគេទេ ដោយបានលើកឡើងថាប្រហែលជាមានការចាប់ខ្លួនដោយមូលហេតុសន្តិសុខ។

28. **ឯកសារ១២៖ ដកស្រង់ពីសៀវភៅ "អំពើប្រល័យពូជសាសន៍ និងការប្រឆាំងនៅអាស៊ីអាគ្នេយ៍** ***(Genocide and Resistance in Southeast Asia)*** **ដោយ** ***Ben Kiernan (2007)***: ក្រុមមេធាវីការពារក្តីស្វែងរកឲ្យទទួលយកសេចក្តីសម្រង់ចេញពីសៀវភៅដែលមានចំណងជើង "អំពើប្រល័យពូជសាសន៍ និងការប្រឆាំងនៅអាស៊ីអគ្នេយ៍" ដែលនិពន្ធដោយលោក **Ben Kiernan** នៅឆ្នាំ ២០០៧[33] ហើយទាក់ទងទៅនឹងប្រជាជនចាមនៅកម្ពុជា ។ សេចក្តីសម្រង់ដែលពាក់ព័ន្ធ[34] អាចរកបាននៅក្នុង**ឯកសារភ្ជាប់សារធារណៈ១២** ។ វាបង្កើតជាមូលដ្ឋាននៃការពិភាក្សារបស់អ្នកប្រវត្តិវិទូ

---

[33] ឯកសារ ១៣ ដាក់លេខឯកសារ **D269/5.1.**

[34] Pp. 272 (ERN 00488405) to 276 (ERN 00488409).

ទាក់ទងនឹងអត្ថិភាពនៃអំពើប្រល័យពូជសាសន៍ និងតួលេខជាមូលដ្ឋានសម្រាប់ការអះអាងនេះ។

29. នៅក្នុងសម្រង់ដែលស្នើ លោក **Kiernan** ជំទាស់ទៅនឹងការលើកឡើងរបស់លោក Osman ដែលថានៅឆ្នាំ ១៩៧៤ ប្រជាជនចាមមានចំនួន ១០% នៃប្រជាជនកម្ពុជាសរុប ឬ ៧០០ ០០០នាក់ ដោយបានកត់សម្គាល់ថា មិនមានភស្តុតាងដែលអាចជឿទុកចិត្តបានសម្រាប់ការអះអាងនេះឡើយ ហើយថាតួលេខរបស់លោក Osman "ច្រើនជាងបីដងនៃចំនួនពិត"។ លោក **Kiernan** សន្និដ្ឋានដោយលើកឡើងថា តួលេខរបស់លោក Osman គឺពឹងផ្អែកទាំងស្រុងលើការអះអាងនៃអតីតកាលដែលជម្រុញឡើងនៅឆ្នាំ ១៩៩៩-២០០០ តាមរយៈការអះអាងរបស់អ្នកត្រូវសម្ភាសន៍ដែលថានៅដើមឆ្នាំ១៩៧០ ពួកគេបាន "ឃើញស្ថិតិ" ឬ "បានស្តាប់ឮការប្រកាសមួយ" ឬការចងចាំរបស់មនុស្សចាស់ដែលមិនបានចងក្រងជាឯកសារ"[35]។ ការវិភាគស៊ីជម្រៅនៃរបាយការណ៍ និងឯកសារប្រវត្តិសាស្ត្រ-ដែលលោក Osman ហាក់ដូចជាមិនបានធ្វើ- លោក **Kiernan** សន្និដ្ឋានថាជនជាតិចាមបានស្លាប់សរុបចំនួន ៩០ ០០០ នាក់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬ ៣៦% នៃប្រជាជនចាមឆ្នាំ ១៩៧៥[36] ។

30. **ឯកសារ១៣៖ អត្ថបទមានចំណងជើង** ***"The Genocide that wasn't",*** **ដោយ** ***Stéphanie Giry*** **(ខែសីហា ២០១៤)៖** ក្រុមមេធាវីការពារក្តីស្វែងរកឱ្យទទួលយកអត្ថបទមួយនិពន្ធដោយ **Stéphanie Giry** នៅក្នុងកាសែត the *New York Review of Books* ហើយទាក់ទងនឹងការបំពេញលក្ខខណ្ឌនៃអំពើប្រល័យពូជសាសន៍ទាក់ទងនឹងព្រឹត្តិការណ៍ដែលកើតឡើងនៅកម្ពុជាចន្លោះឆ្នាំ១៩៧៥ និង ឆ្នាំ ១០៧៩ ។ វាអាចរកបាននៅក្នុង**ឯកសារភ្ជាប់សារធារណៈ១៣** ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ និងមានការសង្ខេបនៃការពិភាក្សាទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងហេតុផលនៃការពិភាក្សាទាំងនេះ។ អត្ថបទនេះបង្កើតជាមូលដ្ឋាននៃការពិភាក្សារបស់អ្នកប្រវត្តិវិទូ ទាក់ទងនឹងអត្ថិភាពនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាពិសេសប្រឆាំងនឹងជនជាតិចាម និង តួលេខជាមូលដ្ឋានសម្រាប់ការអះអាងនេះ។

31. **ឯកសារ១៤៖ អត្ថបទមានចំណងជើង** ***"Cham-Khmer harmony can be an example for***

---

[35] ឯកសា ១៣ នៅទំព័រ ៦ (ERN 00488408).

[36] ឯកសា ១៣ នៅទំព័រ ៧ (ERN 00488409).

*the world", ដោយ Stuart Alan Becker (2011)*: ក្រុមមេធាវីការពារក្តីស្វែងរកឱ្យទទួលយកអត្ថបទមួយនិពន្ធដោយ **Stuart Alan Becker** ក្នុងព្រឹត្តិប័ត្រភ្នំពេញប៉ុស្តិ៍ ហើយទាក់ទងនឹងការទាក់ទងរវាងជនជាតិចាម និង ខ្មែរនៅកម្ពុជា ។ វាអាចរកបាននៅក្នុង**ឯកសារភ្ជាប់សាធារណៈ១៤** ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ២០១១ និងរាយការណ៍ពីលោក Osman ដែលបានលើកឡើងថា "ជនជាតិចាមត្រូវបានសម្លាប់ ដោយសារពួកគេផ្សេងពីគ្នា" ហើយថា "មានគោលនយោបាយមួយនៅឆ្នាំ១៩៧៨ ឱ្យសម្លាប់ជនជាតិចាមទាំងអស់" ។ អត្ថបទនេះបង្កើតជាមូលដ្ឋាននៃការពិភាក្សារបស់អ្នកប្រវត្តិវិទូ ទាក់ទងនឹងអត្ថិភាពនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាពិសេសប្រឆាំងនឹងជនជាតិចាម និងតួលេខជាមូលដ្ឋានសម្រាប់ការអះអាងនេះ។

32. **ឯកសារ១៥៖ អត្ថបទមានចំណងជើង** *"Chams' long wait nearly over"*, ដោយ *Kevin Ponniah និង Koam Chanrasmey (2014)*: ឯកសារ១៥ នេះ គឺជាអត្ថបទមួយដែលនិពន្ធដោយ **Ponniah** និង **Koam Chanrasmey** ដែលត្រូវបានបោះពុម្ពផ្សាយនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ដោយព្រឹត្តិប័ត្រភ្នំពេញប៉ុស្តិ៍ ។ វាអាចរកបាននៅក្នុង**ឯកសារភ្ជាប់សាធារណៈ១៥** ។ លោក **Ponniah** និងលោក **Chanrasmey** ពិភាក្សាពីការជំនុំជម្រះនៅក្នុងសំណុំរឿងបច្ចុប្បនេះ ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងរួមទាំងការពិភាក្សាមួយនៃការពិភាក្សាជាប្រវត្តិសាស្ត្រទាក់ទងនឹងអត្ថិភាពនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាពិសេសប្រឆាំងនឹងជនជាតិចាម និង តួលេខជាមូលដ្ឋានសម្រាប់ការអះអាងនេះ ។

### *(i) ឯកសារត្រូវតែទទួលយកភស្តុតាងដើម្បីជាប្រយោជន៍យុត្តិធម៌*

33. ឯកសារ១៤ និង ឯកសារ១៥ ដែលត្រូវបានបោះពុម្ពផ្សាយរវាងឆ្នាំ២០១១ និងឆ្នាំ២០១៥ មិនអាចរកបាននៅមុនចាប់ផ្តើមសវនាការ ។ ថ្វីបើឯកសារសល់ដែលបានស្នើ ត្រូវបានបោះពុម្ពផ្សាយនៅមុនការបើកការជំនុំជម្រះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះចាត់តាំងលោក Osman ជាអ្នកជំនាញ ត្រូវបានប្រកាសនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ ។ ឯកសារដែលត្រូវស្នើសុំឱ្យបង្ហាញសម្រាប់គោលបំណងជាក់លាក់នៃការជំទាស់ទៅនឹងការលើកឡើងរបស់លោក Osman និងជំនាញរបស់គាត់ ។ ជាលទ្ធផល ឯកសារទាំងនេះមិនត្រូវបានបង្ហាញមុនពេលឡើយ។

34. បន្ថែមពីលើនេះឯកសារដែលបានស្នើ គឺទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលបង្ហាញរួចហើយ

នៅចំពោះមុខអង្គជំនុំជម្រះ រួមទាំងសៀវភៅរបស់លោក Osman ផងដែរ[37]។ វានឹងជាផលប្រយោជន៍ខាងយុត្តិធម៌បើសិនអង្គជំនុំជម្រះវាយតម្លៃភស្តុតាងរបស់លោក Osman និងសៀវភៅរបស់គាត់ ព្រមជាមួយឯកសារទាំងនេះដើម្បីរកឃើញការពិត។ ជាចុងបញ្ចប់ឯកសារដែលស្នើក៏ពាក់ព័ន្ធទៅនឹងការវាយតម្លៃជំនាញរបស់លោក Osman តាមរយៈការជំទាស់នឹងការរកឃើញ និងវិធីសាស្ត្ររបស់គាត់ ។ ហេតុដូច្នេះវាជាតម្លៃភរនីយភាពនៃភស្តុតាងរបស់លោក Osman ។ ការទទួលយកភស្តុតាងនូវឯកសារទាំងនេះ នឹងជួយអង្គជំនុំជម្រះនៅក្នុងការបំភ្លឺលើជំនាញរបស់គាត់ និងលទ្ធភាពពីឯករាជ និង ភាពមិនលម្អៀងរបស់គាត់ ហើយដូច្នេះជាទម្ងន់ចុងក្រោយទៅលើភស្តុតាងរបស់គាត់។ ជាសង្ខេប ការពិនិត្យឡើងវិញនៃឯកសារទាំងនេះដោយអង្គជំនុំជម្រះនឹងជួយបញ្ជាក់ការពិត ។

### *(iii) ឯកសារពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ និងអាចជឿជាក់បាន*

35. ឯកសារដែលបានស្នើគឺ ទាក់ទងនឹងការចោទប្រកាន់អំពីការប្រព្រឹត្តមកលើជនជាតិចាម និងការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍[38]។ ខ្លឹមសាររបស់វាគឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងភស្តុតាងដែលនឹងផ្តល់ដោយលោក ឧស្មាន នៅក្នុងផ្នែកនៃការប្រព្រឹត្តលើជនជាតិចាម[39] និងផ្តល់ជាពន្លឺខុសគ្នាទៅនឹងសៀវភៅរបស់លោក ឧស្មាន ទាក់ទងនឹងចំនួនជនជាតិចាមដែលបានស្លាប់នៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

36. ឯកសារនៅក្នុងប្រភេទ III ទាំងអស់ត្រូវបានសរសេរដោយអ្នកជំនាញ ឬក៏អ្នកកាសែត[40] ហើយ

---

[37] សូមមើលជើងទំព័រលេខ៩ ខាងលើ។

[38] **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៧៤៥ ដល់ ៧៩០។

[39] ឯកសារ **E305/6.4** "ឧបសម្ព័ន្ធ III បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ" ទំព័រ ៤៧ ចូលលេខ ៦។

[40] **Mr Kiernan** ជា សាស្ត្រាចារ្យប្រវត្តិសាស្ត្រ និងជាស្ថាបនិកកម្មវិធីសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅសកលវិទ្យាល័យយែល។ នៅក្នុងសំណុំរឿង ០០២/០១ គាត់ត្រូវបានគ្រោងមកផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីជំនាញ តែទោះជាយ៉ាងណាក៏ដោយ គាត់មិនបានផ្តល់សក្ខីកម្មទេ ដោយសារតែអង្គជំនុំជម្រះបានបដិសេធស្តាប់ចម្លើយរបស់គាត់ ដោយលើកឡើងថា គាត់ជា "អ្នកជំនាញមិនសហការ" **E166/1/4** "សក្ខីកម្ម Benedict KIERNAN ដែលភាគីបានស្នើសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ១៣ មិថុនា ឆ្នាំ ២០១២ ទំព័រ ២។ លោក **Shor** ជាអ្នកនិពន្ធ និងអ្នកកាសែត។ គាត់បានផ្តល់សក្ខីកម្មជាអ្នកជំនាញនៅចំពោះមុខ អវតក ក្នុងសំណុំរឿង ០០២/០១ នឹងត្រូវបានយោងនៅក្នុងសាលក្រមជាង១០០ដង។ **Mr Vickery** ជាអ្នកប្រវត្តិសាស្ត្រជំនាញខាងប្រវត្តិសាស្ត្របុរាណ និងទំនើបរបស់កម្ពុជា។ លោក បូរ៉ា ជាមេធាវីខ្មែរ។ **Giry** ជាអ្នកកាសែត

ត្រូវបានបោះពុម្ពដោយកាសែត ទនានុប្បវត្តិ អ្នកបោះពុម្ពផ្សាយ និង គេហទំព័រល្បីៗ។ អាស្រ័យដោយហេតុផលទាំងនេះហើយ មេធាវីការពារក្ដីបានបង្ហាញអំពី ភាពអាចជឿជាក់បាននៃឯកសារតាមរយៈ *ការពិនិត្យជាបឋម*។

## IV. **សំណើសុំ**

37. ដោយសារហេតុផលទាំងអស់ដែលបានលើកឡើងនេះ មេធាវីការពារក្ដីស្នើសុំដោយគោរពដល់អង្គជំនុំជម្រះឲ្យទទួលយកឯកសារទាំង១៥នេះ ដាក់ចូលក្នុងសំណុំរឿង ០០២/០២។

**សហមេធាវីការពារក្ដីរបស់ នួន ជា**

**សុន អរុណ** **Victor KOPPE**

---

អ្នកត្រួតពិនិត្យនៃកាសែត New York Time។ **Becker, Mr Ponniah** និង **Mr Chanrasmey** ជាអ្នកកាសែតភ្នំពេញប៉ុស្តិ៍។ **Wright** និង **Narim** ធ្វើការ (ឬបានធ្វើការ) ជាអ្នកកាសែតខេមបូឌៀដេលី។